# 技能実習生の友

## មិត្តរបស់សិក្ខាកាមបណ្តុះបណ្តាលជំនាញ

មេសា 2023 និទាឃរដូវ

### ប្រធានបទ

យល់ដឹងតាមរយៈតុក្កតាជប៉ុន អំពីអារម្មណ៍ជនជាតិជប៉ុន "សូមគោរពច្បាប់ចរាចរសម្រាប់កង់"
◇ប្រសិនបើសិក្ខាកាមបណ្តុះបណ្តាលជំនាញមានផ្ទៃពោះ････？　◇រដូវភ្លៀងធ្លាក់ "រដូវវស្សា" ~ របៀបរស់នៅ និងការប្រុងប្រយ័ត្ន ~
កុគីហ្គុណុម៉ុរិ "អក្សរតូច"

## យល់ដឹងតាមរយៈតុក្កតាជប៉ុន អំពីអារម្មណ៍ជនជាតិជប៉ុន

— សូមគោរពច្បាប់ចរាចរសម្រាប់កង់ —




**ចម្លើយត្រូវគឺ... ជិះខុសរបៀបទាំងអស់!**

1. វាមានគ្រោះថ្នាក់ណាស់ ក្នុងការនិយាយទូរស័ព្ទពេលកំពុងជិះកង់។
2. កង់គឺត្រូវធ្វើចរាចរប្រកាន់ឆ្វេង។
3. បើកបរប្រើឆ័ត្រគឺមានគ្រោះថ្នាក់ណាស់ ព្រោះមើលមុខមិនឃើញ។
4. សូមកុំជិះកង់មួយពីរនាក់។
5. ជិះកង់ទន្ទឹមគ្នានិងជជែកគ្នាបណ្តើរ គឺរាំងអ្នកចរាចរផ្សេងទៀត។

សិក្ខាកាមបណ្តុះបណ្តាលជំនាញភាគច្រើនប្រើកង់។ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ក៏ដូចជា ចៀសវាងការធ្វើអោយរបួសដល់អ្នកដទៃ ដូចជាអ្នកថ្មើរជើងជាដើម សូមគោរពច្បាប់ចរាចរកង់ទាំងអស់គ្នា។

ហាងលក់ឯកសាររៀនអនឡាញរបស់ JITCO មានលក់ឌីវីឌី "ចងចាំសុវត្ថិភាពចរាចររបស់ជប៉ុនតាមរយៈ Q&A – ច្បាប់អំពីការដើរ និងជិះកង់"។ លើសពីនេះទៀត វីដេអូចែកចាយដោយគិតប្រាក់មាននៅ "គេហទំព័រចែកចាយឯកសាររៀនបែបអេឡិចត្រូនិក JITCO" ដែលទើបដំណើរការថ្មីនេះ។

"មិត្តរបស់សិក្ខាកាមបណ្តុះបណ្តាលជំនាញ" ត្រូវបានបោះពុម្ពជាភាសាជប៉ុន ជាមួយស៊ីងសំរាប់អានហ្វីរិហ្គាណា និង ប្រាំបួនភាសាទៀត (វៀតណាម ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ កម្ពុជា មីយ៉ាន់ម៉ា ម៉ុងហ្គោលី និងអង់គ្លេស) អំពីព័ត៌មានដែលមានប្រយោជន៍ក្នុងជីវិតប្រចាំថ្ងៃនៅប្រទេសជប៉ុន ឯកសារបង្រៀនភាសាជប៉ុន តុក្កតាស៊ុមបួនជាដើម សម្រាប់សិក្ខាកាមបណ្តុះបណ្តាលជំនាញ និង សិក្ខាកាមបណ្តុះបណ្តាលបច្ចេកទេស ។ យើងសង្ឃឹមថាអ្នកទាំងអស់គ្នានឹងអានវា!



JITCO

# ប្រសិនបើសិក្ខាកាមបណ្តុះបណ្តាលជំនាញមានផ្ទៃពោះ····?

យោងតាមទិន្នន័យ ដែលចេញផ្សាយដោយអង្គការបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ជនបរទេស (OTIT) ក្នុងខែធ្នូ ឆ្នាំ2022 នៅក្នុងបទសម្ភាសន៍ជាមួយសិក្ខាកាមបណ្តុះបណ្តាលជំនាញ សិក្ខាកាមប្រមាណ 60% បានឆ្លើយថាពួកគេបានទទួលការពន្យល់អំពីការហាមឃាត់ ទាក់ទងការចាត់ទុកជាចាញ់ប្រៀបដោយមូលហេតុនៃការមានផ្ទៃពោះ ឬការសម្រាលកូន។ ម្យ៉ាងវិញទៀត សិក្ខាកាមបណ្តុះបណ្តាលជំនាញប្រហែលម្នាក់ក្នុងចំណោម៤នាក់ ត្រូវបានប្រាប់ជាពិសេសដោយអង្គភាពបញ្ជូនពលករថា ពួកគេនឹងមិនអាចបន្តការបណ្តុះបណ្តាលបានទេ ប្រសិនបើពួកគេមានផ្ទៃពោះ។ នៅប្រទេសជប៉ុន វាត្រូវបានហាមឃាត់ដោយច្បាប់សម្រាប់ការបញ្ឈប់កម្មករ (រួមទាំងសិក្ខាកាមបណ្តុះបណ្តាលជំនាញ) ឱ្យឈប់ពីការងារដោយសារតែពួកគេមានផ្ទៃពោះ។

នៅផ្នែកនេះ នឹងរៀបរាប់អំពីអ្វីដែលត្រូវធ្វើ ប្រសិនបើសិក្ខាកាមបណ្តុះបណ្តាលជំនាញរកឃើញថាខ្លួននាងមានផ្ទៃពោះ។

## Q តើគួរធ្វើដូចម្តេចប្រសិនបើមានផ្ទៃពោះ?



- ទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេសសម្ភព។
- ពិគ្រោះជាមួយអ្នកនៅក្រុមហ៊ុន ឬស្ថាប័នគ្រប់គ្រង។
- រាយការណ៍ពីការមានផ្ទៃពោះរបស់អ្នកនៅការិយាល័យខេត្តឬក្រុងដែលអ្នកស្នាក់នៅ ។

## Q តើនឹងមានអ្វីកើតឡើងចំពោះសិក្ខាកាម?

- ដោយសារហេតុផលថាសិក្ខាកាមមានផ្ទៃពោះ ទាំងស្ថាប័នគ្រប់គ្រង ឬអ្នកផ្តល់ការបណ្តុះបណ្តាលសិក្ខាកាម មិនអាចបញ្ចប់ការបណ្តុះបណ្តាលជំនាញបានទេ ។
- តាមសេចក្តីប្រាថ្នាចង់បាន សិក្ខាកាមអាចឈប់សម្រាកពីការងារមុនពេលសម្រាលកូន ចាប់ពី6សប្តាហ៍មុនថ្ងៃគ្រោងសម្រាលកូន។ តាមច្បាប់នៅប្រទេសជប៉ុន ដើម្បីសុខភាពរាងកាយរបស់ម្តាយ គឺមិនតម្រូវឲ្យធ្វើការទេ រយៈពេល 8សប្តាហ៍ក្រោយថ្ងៃសម្រាលកូន។ ប្រាក់ខែពេលមិនធ្វើការ គឺអាស្រ័យលើច្បាប់របស់ក្រុមហ៊ុន ប៉ុន្តែប្រសិនបើគ្មានប្រាក់ខែទេ ធានារ៉ាប់រងសុខភាពនឹងផ្តល់ប្រាក់ឧបត្ថម្ភមាតុភាព (ប្រហែល 60% នៃប្រាក់ឈ្នួល)។
- តាមសេចក្តីប្រាថ្នាចង់បាន អ្នកអាចផ្អាកការបណ្តុះបណ្តាលជំនាញសិន ឬត្រឡប់ទៅប្រទេសកំណើតរបស់អ្នកជាបណ្តោះអាសន្ន ដើម្បីសម្រាលកូន ហើយបន្តការបណ្តុះបណ្តាលជំនាញឡើងវិញ បន្ទាប់ពីសម្រាលរួច។ សូមពិគ្រោះជាមួយស្ថាប័នគ្រប់គ្រង ឬក្រុមហ៊ុនអ្នក។
- ប្រសិនបើអ្នកបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អ្នកក៏អាចប្រើប្រព័ន្ធឈប់សម្រាកថែទាំទារកផងដែរ។ លើសពីនេះទៀត មានប្រព័ន្ធប្រាក់ឧបត្ថម្ភការសម្រាលនិងមើលថែទារក របស់ ធានារ៉ាប់រងសុខភាពផងដែរ។



## Q តើអាចពិគ្រោះយោបល់នៅឯណា?

នៅពេលដែលអ្នកដឹងថាអ្នកមានផ្ទៃពោះ ដំបូងអ្នកត្រូវពិគ្រោះជាមួយអ្នកជុំវិញខ្លួននឹងអ្នក ដូចជាក្រុមហ៊ុន ឬ ស្ថាប័នគ្រប់គ្រងរបស់អ្នក។ អ្នកនឹងត្រូវសម្របសម្រួលជាមួយពួកគេទាក់ទងនឹងការបន្តការបណ្តុះបណ្តាលជំនាញរបស់អ្នក ការត្រឡប់ទៅប្រទេសកំណើតបណ្តោះអាសន្ន នីតិវិធីទាក់ទងនឹងការមានផ្ទៃពោះ និងការសម្រាលកូន ការទៅមន្ទីរពេទ្យ និងស្ថានភាពលំនៅដ្ឋានរបស់កូនអ្នកក្នុងករណីដែលសម្រាល។

អង្គការបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ជនបរទេស (OTIT) ក៏មានសេវាប្រឹក្សាយោបល់ផងដែរ។
ភាសាខ្មែរ
ទូរស័ព្ទ៖ 0120-250-366
ថ្ងៃព្រហស្បតិ៍ (11:00-19:00)

ទទួលពាក្យតាមទម្រង់អនឡាញ 24ម៉ោង
https://www.otit.go.jp/notebook_km/

នៅពេលដែលអ្នកដឹងថាអ្នកមានផ្ទៃពោះ សូមកុំបារម្ភតែម្នាក់ឯង ប៉ុន្តែត្រូវប្រឹក្សាជាមួយដៃគូរបស់អ្នក ក្រុមគ្រួសារ ក្រុមហ៊ុន ស្ថាប័នគ្រប់គ្រង OTIT ឬទីប្រឹក្សាសាធារណៈ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ការមានផ្ទៃពោះ និងការសម្រាលកូនមានឥទ្ធិពលយ៉ាងខ្លាំងដល់អនាគតរបស់អ្នក ដូចនេះទាមទារអោយធ្វើប្រកបដោយទទួលដឹង និង ទទួលខុសត្រូវ។

**<ព័ត៌មានសម្រាប់ឯកសារយោង>**

សៀវភៅណែនាំសម្រាប់សិក្ខាកាមបណ្តុះបណ្តាលជំនាញក៏រួមបញ្ចូលព័ត៌មានអំពីការមានផ្ទៃពោះ និងការសម្រាលកូនផងដែរ។ លើសពីនេះទៀត "សៀវភៅណែនាំអំពីការរស់នៅ និងការងារ" ដែលបានបង្ហោះនៅលើគេហទំព័ររបស់ទីភ្នាក់ងារត្រួតពិនិត្យអន្តោប្រវេសន៍សម្រាប់ជនបរទេស ក៏មានផ្តល់ព័ត៌មានស្តីពីការសម្រាលកូន និងការចិញ្ចឹមកូន ព្រមទាំងព័ត៌មានផ្សេងៗនៃការរស់នៅ ប្រទេសជប៉ុន ជាភាសា "ជប៉ុនងាយៗ" និង 13 ភាសាបរទេសផ្សេងទៀត។ លើសពីនេះ សេវាពិគ្រោះយោបល់សម្រាប់ជនបរទេសក៏មាននៅការិយាល័យខេត្ត និងក្រុងផងដែរ។

## រដូវភ្លៀងធ្លាក់ "រដូវវស្សា" ~ របៀបរស់នៅ និងការប្រុងប្រយ័ត្ន ~



នៅប្រទេសជប៉ុន លើកលែងតែកោះហុកកៃដូ និង តំបន់ខ្លះនៅតូហុគឺ រដូវមានភ្លៀងធ្លាក់ចាប់ផ្តើមពីចុងខែឧសភា ដល់ ដើមខែឬពាក់កណ្តាលខែកក្កដា។ រដូវមានភ្លៀងធ្លាក់នេះត្រូវបានគេហៅថា "រដូវវស្សា(ដែលភាសាជប៉ុនហៅថា ត្សឹយឹ)" នៅរដូវនេះមានពពកនិងភ្លៀងប៉ុន្មានថ្ងៃជាប់ៗគ្នា។ រដូវវស្សានេះមានដោយសារតែខ្សែបន្ទាត់ព្រំប្រទល់សម្ពាធខ្ពស់ទាបនៃរដូវវស្សា ដែលវារំកិលខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ ពីទិសខាងត្បូងទៅខាងជើងនៃប្រជុំកោះជប៉ុន ហើយទីភ្នាក់ងារឧតុនិយមជប៉ុននិងប្រកាសកាលបរិច្ឆេទនៃការចាប់ផ្តើម និងចុងបញ្ចប់នៃរដូវវស្សានេះ។ វាហាក់បីដូចជាមានមនុស្សច្រើនជាងធម្មតា យកចិត្តទុកដាក់លើការព្យាករណ៍អាកាសធាតុក្នុងកំឡុងពេលដែលមានភ្លៀងធ្លាក់ច្រើន។ សីតុណ្ហភាពប្រែប្រួលយ៉ាងខ្លាំងអាស្រ័យតាមថ្ងៃ ហើយថ្ងៃខ្លះមានអារម្មណ៍ត្រជាក់បន្តិច រីឯថ្ងៃខ្លះទៀតមានសំណើមខ្ពស់ និងក្តៅស្អុះស្អាប់ ដែលធ្វើឲ្យយើងពិបាកគ្រប់គ្រងសុខភាពរាងកាយរបស់យើង។ ប្រសិនបើអ្នកមិនអាចគ្រប់គ្រងសីតុណ្ហភាពរាងកាយរបស់អ្នកឱ្យបានល្អទេ អ្នកអាចនឹងឈឺ ដូច្នេះកុំធុញទ្រាន់នឹង ការប្តូរសម្លៀកបំពាក់របស់អ្នក ការដេកនិងបរិភោគឱ្យបានល្អ ដើម្បីរក្សាកម្លាំងកាយរបស់អ្នកអោយមាំមួន។ រដូវនេះក៏ជាពេលមួយដែលការពុលចំណីអាហារអាចកើតឡើងដែរ ព្រោះ ងាយនឹងដុះផ្សិត និងបាក់តេរីងាយកកើតឡើង។ ដូចនេះសូមយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រឿងធ្វើម្ហូប និងព្យាយាមធ្វើការរក្សាភាពស្អាតអោយច្រើនជាងធម្មតា។

ក៏ប៉ុន្តែ ទឹកភ្លៀងដែលធ្លាក់ច្រើនក្នុងរដូវវស្សានេះ ត្រូវបានរក្សាទុកក្នុងទំនប់ទឹក ហើយក្លាយជាទឹកផឹករបស់ប្រជាជននៅពាក់កណ្តាលរដូវក្តៅនៅពេលដែលគ្រោះរាំងស្ងួតកើតឡើង។ លើសពីនេះ ទឹកភ្លៀងដែលបានរក្សាទុកនោះមានតួនាទីយ៉ាងសំខាន់ ជាទឹកកសិកម្មដែលប្រើប្រាស់សម្រាប់ការធ្វើកសិកម្ម ហើយវាក៏ជា "ទឹកភ្លៀងអំណោយផល" ដែលមិនអាចខ្វះបានសម្រាប់ជីវិតជនជាតិជប៉ុន។

ពេលភ្លៀងចេះតែបន្តធ្លាក់ យើងងាយនឹងមានការបាក់ទឹកចិត្ត ប៉ុន្តែក៏មានវិធីដើម្បីរីករាយសម្រាប់តែរដូវវស្សានេះផងដែរ។ ផ្កាផ្កាយព្រឹក គឺជាផ្កាដែលរីកក្នុងរដូវវស្សានេះតែម្តង ហើយមានកន្លែងមើលផ្កាផ្កាយព្រឹកល្បីៗជាច្រើននៅប្រទេសជប៉ុន។ ផ្កាពណ៌ស្វាយ ឬពណ៌ផ្កាឈូក និងស្លឹកបៃតងកាន់តែមានភាពរស់រវើកនៅពេលដែលវាសើមក្រោយពេលភ្លៀង ដូច្នេះគេណែនាំឱ្យថតរូប ផ្កាផ្កាយព្រឹក នៅថ្ងៃដែលមានភ្លៀង។

វាជារដូវដ៏លំបាកមួយសម្រាប់សិក្ខាកាមដែលមិនស៊ាំនឹងអាកាសធាតុជប៉ុន ប៉ុន្តែសូមឱ្យឆ្លងកាត់ "រដូវវស្សា" ប្រកបដោយសុខភាពល្អតាមរយៈការខំប្រឹងប្រែងផ្សេងៗ។

## កុគឹហ្គុណុម៉ុរិ

នេះជាឯកសារសិក្សាសម្រាប់រៀនរបៀបប្រើវាក្យស័ព្ទនិង អក្សរកាន់ជី ភាសាជប៉ុន។ សូមរីករាយក្នុងការគិតរកចម្លើយទាំងអស់គ្នា។
(ចម្លើយមាននៅទំព័របន្ទាប់)




©毎日小学生新聞　ហាមថតចម្លង ឬចែកចាយបន្ត

## រូបថតមួយសន្លឹក របស់សិក្ខាកាមបណ្ដុះបណ្ដាលជំនាញ ខែនេះ



សិក្ខាកាមមកពីប្រទេសហ្វីលីពីន បាននាំគ្នាទៅភ្នំហ្វូជីជាលើកដំបូង។ គាត់មានការស្ញប់ស្ញែងដោយទឹកស្អាតនៅ អុស៊ិណុហាក់កៃ ខេត្ត យ៉ាម៉ាណាស៊ិ! ក្ដីសុបិនមួយ ក្នុងការទៅកន្លែងដ៏ស្រស់ស្អាតនៅប្រទេសជប៉ុនបានក្លាយជាការពិត ហើយក៏មានស្នាមញញឹមដ៏អស្ចារ្យនៅលើមុខរបស់គាត់។

*បានផុសកាលពី ខែកក្កដា ឆ្នាំ២០២២

（日本メカニック株式会社）

យើងបានដាក់រូបមួយសន្លឹកនេះដោយបានរើសពី "ទិវាសិក្ខាកាមបណ្ដុះបណ្ដាលជំនាញ" ដែលបានបង្ហោះនៅលើគេហទំព័រ JITCOពីសំណាក់អង្គការទទួលសិក្ខាកាមជាដើម ។គេហទំព័រ"ទិវាសិក្ខាកាមបណ្ដុះបណ្ដាលជំនាញ" និង ពាក្យស្នើសុំ អាចមើលនៅទីនេះបាន ។

（https://www.jitco.or.jp/ja/days/）

### សេចក្ដីជូនដំណឹង ការប្រកួតតែងសេចក្ដីភាសាជប៉ុន លើកទី31 សំរាប់សិក្ខាកាមបណ្ដុះបណ្ដាលជំនាញ និង សិក្ខាកាមបំពាក់បំប៉នបច្ចេកទេស

ចាប់ពីថ្ងៃទី៣ ខែមេសា (ច័ន្ទ) តទៅ យើងខ្ញុំចាប់ទទួលពាក្យសំរាប់ ការប្រកួតប្រជែងតែងសេចក្ដីជាភាសាជប៉ុន លើកទី31។ ថ្ងៃផុតកំណត់ទទួលពាក្យគឺ ថ្ងៃទី១២ ខែឧសភា (សុក្រ)។ សម្រាប់ព័ត៌មានលម្អិតអំពីសេចក្ដីជូនដំណឹងនៃការដាក់ពាក្យ មានចុះផ្សាយ នៅលើគេហទំព័ររបស់ JITCO (https://www.jitco.or.jp/)និង មានសរសេរនៅកន្លែងជូនដំណឹង របស់ កន្លែងផ្ទុកឯកសារភាសាជប៉ុន JITCO (https://hiroba.jitco.or.jp/) យើងខ្ញុំទន្ទឹងរងចាំមើលតែងសេចក្ដីរបស់អ្នកទាំងអស់គ្នា ។

### សូមប្រាប់ប្រធានបទដែលអ្នកចង់ឱ្យយើងលើកឡើងក្នុង "មិត្តរបស់សិក្ខាកាមបណ្ដុះបណ្ដាលជំនាញ"!

សូមប្រើទម្រង់បែបបទនៅខាងស្ដាំដើម្បីផ្ញើមកយើងនូវមតិយោបល់ និងការចាប់អារម្មណ៍របស់អ្នកអំពី "មិត្តរបស់សិក្ខាកាមបណ្ដុះបណ្ដាលជំនាញ" ឬ ប្រធានបទដែលអ្នកចង់ឱ្យយើងលើកឡើង និងប្រធានបទពេញនិយមដែលអ្នកចាប់អារម្មណ៍ ។

◆こくごこたえ




「あ」はふと気づいたり、思い出した時に、「ああ」の後には「よかった・そうですか」などが続き、安心したり、納得したりした時に言います。驚いたり、思いついたりした時に、思わず出るのが「あっ」です。

文字とちがって、声に出した音は、高低も調子も、みなそれぞれです。「ああ、いい気持ち」という時と、「ああ、困った」という時では、声のトーンもちがうでしょう。目で見る言葉と、耳で聞く言葉。何気ない「あ」にも、気持ちが表れますね。

"あ(អូ)" ប្រើពេលអ្នកសម្គាល់ឃើញ ឬនឹកឃើញអ្វីមួយ ហើយ "ああ(អ្ហា)" ដែលភ្ជាប់ដោយឃ្លា "ល្អមែន ឬ អញ្ចឹងសោះ" គេប្រើនៅពេលអ្នកមានអារម្មណ៍សុខចិត្តឬពេញចិត្ត។ ពេលអ្នកភ្ញាក់ផ្អើលឬនឹកឃើញគំនិតមួយ សម្លេងដែលចេញទាំងមិនដឹងខ្លួនគឺ "あっ(អ្ហា:)" ។ មិនដូចគ្នានឹងអក្សរទេ សម្លេងដែលបញ្ចេញគឺខុសគ្នា ទាំងកម្ពស់និងការលើកដាក់។ ការលើកដាក់សម្លេងខុសគ្នា ពេលអ្នកនិយាយថា "អ្ហា(ああ) ខ្ញុំមានអារម្មណ៍ល្អ" និង "អ្ហា(ああ) ខ្ញុំមានបញ្ហា" ។ ពាក្យដែលអ្នកឃើញនឹងភ្នែក និងពាក្យដែលឮដោយត្រចៀក មានអារម្មណ៍របស់អ្នកលេចចេញឡើង សូម្បីតែនៅក្នុងពាក្យធម្មតា "あ"។


技能実習生・研修生向け母国語情報誌

# 技能実習生の友

2023年4月　春季号

2023年4月1日発行

発　行　公益財団法人 国際人材協力機構（JITCO）
総務部広報室
〒108-0023
東京都港区芝浦2-11-5
五十嵐ビルディング

電　話　03-4306-1166（ダイヤルイン）

JITCO ホームページ　https://www.jitco.or.jp/